Declassified to Public
12 June 2020

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 02 / 2015
ម៉ោង (Time/Heure) : 14 : 55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លេខ / N°: C1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No:004/07-09-2009-ECCC-OCIJ**

# ដីកាបង្គាប់ឱ្យនាំខ្លួន
# Arrest Warrant
# Mandat d'amener

ខ្ញុំ **Mark B. Harmon** សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អន្តរជាតិ") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ**វិធាន ១១, ១៥, ២១, ២២,៤១, ៤២, ៤៥, ៥១, ៥៥, ៥៧ និង៧២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងនឹងសំណុំរឿង ០០៤ ដែលបានដាក់ចូលក្នុងសំណុំរឿងនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ")[1]។

---

[1]សំណុំរឿង០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣"* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០០៨។ សំណុំរឿង០០៤ ឯកសារD1/1*ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១")[2]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២")[3]។

**បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពានក្រមព្រហ្មទណ្ឌ **ឆ្នាំ ១៩៥៦ អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩** និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

**បានឃើញថា** អ៊ឹម ចែម គឺជាជនសង្ស័យម្នាក់ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២។

**បានឃើញ**ព័ត៌មានដូចខាងក្រោមទាក់ទងនឹងអត្តសញ្ញាណរបស់អ៊ឹម ចែម

ភេទ៖ ស្រី

ថ្ងៃខែឆ្នាំកំណើត៖ ១៩៤៦

ស្រុកកំណើត៖ ភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ

សញ្ជាតិ៖ ខ្មែរ

ទីលំនៅបច្ចុប្បន្ន៖ ភូមិអូរ អង្រែ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

មានរូបថតដូចបានភ្ជាប់ជាមួយ[4]

---

[2]សំណុំរឿង ០០៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។

[3]សំណុំរឿង ០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។





CO-INVESTIGATING JUDGES

**បានឃើញ**ថា នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានចេញដីកាកោះហៅអ៊ឹម ចែម ឲ្យមកបង្ហាញនៅ អ.វ.ត.ក សម្រាប់ការបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤[5]។

**បានឃើញ**ថា លោក Cristian Baudesson អ្នកស៊ើបអង្កេតនៅ អ.វ.ត.ក បានប្រគល់ដីកាកោះនេះជូនអ៊ឹម ចែម នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤[6]។

**បានឃើញ**ថា អ៊ឹម ចែម មិនបានមកបង្ហាញខ្លួនសម្រាប់ការបង្ហាញខ្លួនលើកដំបូងនេះ។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

អាស្រ័យហេតុនេះ **បង្គាប់** នគរបាលយុត្តិធម៌ ឲ្យអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននេះ។

នគរបាលយុត្តិធម៌ មិនត្រូវចូលទីលំនៅដ្ឋានរបស់អ៊ឹម ចែម មុនម៉ោង ៦ ព្រឹក ឬក្រោយម៉ោង ៦ ល្ងាច ហើយ នគរបាលយុត្តិធម៌ ត្រូវជូនដំណឹង ស.ច.ស.អន្តរជាតិ អំពីការលំបាកណាមួយនៅក្នុងការបំពេញបេសកកម្មនេះ។

នគរបាលយុត្តិធម៌ ត្រូវនាំ អ៊ឹម ចែម មកបង្ហាញខ្លួននៅចំពោះមុខ ស.ច.ស.អន្តរជាតិ សម្រាប់ការបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើ ដោយសារកាលៈទេសៈ អ៊ឹម ចែម មិនអាចត្រូវបាននាំខ្លួនមកបង្ហាញនៅចំពោះមុខ ស.ច.ស.អន្តរជាតិ បានភ្លាមៗទេ គាត់ត្រូវដាក់ឲ្យជាប់ឃុំខ្លួនបណ្តោះអាសន្ននៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់ អ.វ.ត.ក នៅពេលណាដែលអាចធ្វើទៅបាន ហើយត្រូវនាំខ្លួនមកបង្ហាញនៅចំពោះមុខ ស.ច.ស.អន្តរជាតិ ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

អ៊ឹម ចែម មានសិទ្ធិដូចខាងក្រោមដោយអនុលោមតាមវិធានផ្ទៃក្នុង៖

- សិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់គាត់ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ១១, ២១ និង២២ និងបទបញ្ជារដ្ឋបាលដែលចូលជាធរមាន។

---

[4]សំណុំរឿង ០០៤ ឯកសារ A150.1 *រូបថតរបស់អ៊ឹម ចែម* ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

[5]សំណុំរឿង ០០៤ ឯកសារ A150 *ដីកាកោះហៅអ៊ឹម ចែម ឲ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

[6]សំណុំរឿង ០០៤ ឯកសារ A150/1 *កំណត់ហេតុនៃការប្រគល់ដីកាកោះ* ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤។

01065047



- សិទ្ធិមានវត្តមានរបស់មេធាវីនៅក្នុងអំឡុងពេលនៃការបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធានផ្ទៃក្នុង ៥៧។

- សិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ អនុលោមតាមវិធានផ្ទៃក្នុង ៥៧។

- សិទ្ធិផ្តល់ចម្លើយដោយមានកំណត់ហេតុ ដោយមានវត្តមានរបស់មេធាវី នៅក្នុងអំឡុងពេលនៃការបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធានផ្ទៃក្នុង ៥៧ និង

- សិទ្ធិពិគ្រោះជាមួយមេធាវី មុនពេលគាត់ត្រូវបានសួរចម្លើយ នៅក្នុងដំណាក់កាលណាមួយនៃការស៊ើបអង្កេតរបស់តុលាការ។

ប្រសិនបើគាត់ត្រូវដាក់ឲ្យជាប់ឃុំខ្លួនបណ្តោះអាសន្ន ដោយសារថា គាត់មិនអាចត្រូវបាននាំខ្លួនមកបង្ហាញនៅចំពោះមុខ ស.ច.ស.អន្តរជាតិ បានភ្លាមៗទេនោះ គាត់មានសិទ្ធិដូចខាងក្រោម អនុលោមតាមវិធានផ្ទៃក្នុង៖

- សិទ្ធិស្នើសុំជួបមេធាវី ហើយមេធាវីនោះនឹងត្រូវបានជូនដំណឹងអំពីសំណើនេះភ្លាមៗ តាមមធ្យោបាយទាំងអស់ដែលមាន និង

- សិទ្ធិជួបមេធាវីបែបនោះ ឬក៏ប្រសិនបើចំណុចនេះមិនអាចធ្វើបាន គឺត្រូវជួបមេធាវីម្នាក់ដែលផ្តល់ជូនដោយអង្គភាពគាំពារការការពារក្តី ដោយជួបបានរយៈពេលអតិបរមាណ ៣០ (សាបសិប) នាទីមុនពេលគាត់ត្រូវបានបង្ហាញខ្លួននៅចំពោះមុខ ស.ច.ស.អន្តរជាតិ។ មេធាវីរូបនេះត្រូវមានសិទ្ធិមានវត្តមាននៅក្នុងអំឡុងពេលនៃការឃុំខ្លួនគ្រប់គ្រងដោយនគរបាល អាស្រ័យតាមលក្ខខណ្ឌតម្រូវរដ្ឋបាលរបស់មន្ទីរឃុំឃាំងបណ្តោះអាសន្ន។

ស.ច.ស.អន្តរជាតិ ស្នើថា អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ត្រូវផ្តល់ជំនួយណាដែលអាចស្នើសុំដោយនគរបាលយុត្តិធម៌នៅក្នុងការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននេះ។

០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ៖ C1

ភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤

ចៅក្រម Mark B. Harmon

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

**International Co- Investigating Judge**

**Co-juge d'instruction International**